(០៧)

# ច្បាប់ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤

# ច្បាប់

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ៦១ ជំពូកទី ២ ស្តីអំពី ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

## បង្គាប់

មាត្រា ១. ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភា បានអនុម័ត· នៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ១៩៩៤ ។

មាត្រា ២. ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជវាំងភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង ដោយព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

# ច្បាប់

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃ គណៈរដ្ឋមន្ត្រី

### ជំពូកទី ១

### តួនាទីនិងសមាសភាពរាជរដ្ឋាភិបាល

មាត្រា ១.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានភារកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តន៍ច្បាប់និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិនិងអង្គការតុលាការ ។

រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់ខ្លួន។

មាត្រា ២.-

រាជរដ្ឋាភិបាលគ្រប់គ្រង បញ្ជា ប្រើប្រាស់យោធា នគរបាល កម្លាំងប្រដាប់អាវុធផ្សេងៗទៀត និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន ។

មាត្រា ៣.-

រាជរដ្ឋាភិបាលមិនដាក់កិច្ចការទូទៅរបស់រដ្ឋក្រៅកម្មវិធីនយោបាយ និងផែនការរដ្ឋដែលរដ្ឋសភាបានអនុម័ត ។

មាត្រា ៤.-

សមាសភាពនៃរាជរដ្ឋាភិបាលមាន ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី

- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី
- រដ្ឋលេខាធិការ

ក្នុងករណីដែលព្រះមហាក្សត្រទ្រង់បានតែងតាំងនាយករដ្ឋមន្ត្រីទី ១ មួយរូប និង នាយករដ្ឋមន្ត្រីទី ២ មួយរូប តាមមាត្រា ១៣៨ នៃរដ្ឋធម្មនុញ្ញ នាយករដ្ឋមន្ត្រីទាំងពីររូបនេះ មានសិទ្ធិអំណាច និង បុព្វសិទ្ធិស្មើគ្នា ដើម្បីដឹកនាំរាជរដ្ឋាភិបាល ដោយឈរលើគោលការណ៍សហព័ទ្ធសំរេច ។

មាត្រា ៥._

នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើស យកក្នុងចំណោមសមាជិករដ្ឋសភា ឬ ក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណៈបក្ស មានតំណាងនៅក្នុងរដ្ឋសភា។ សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានសេចក្ដីអនុម័តទុកចិត្តពីរដ្ឋសភា ។

មាត្រា ៦._

អនុរដ្ឋលេខាធិការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ អនុរដ្ឋលេខាធិការមិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។ នៅពេលណា ដែលរាជរដ្ឋាភិបាលត្រូវបានលាលែងបូរលាយ អនុរដ្ឋលេខាធិការក៏ត្រូវអស់តំណែងដែរ ។

មាត្រា ៧._

នៅពេលផុតនីតិកាលរបស់រដ្ឋសភា ឬពេលផ្លាស់ប្ដូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែល ត្រូវចេញពីតំណែង មានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

## ជំពូកទី ២
## គណៈរដ្ឋមន្ត្រីនិងសមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី

មាត្រា ៨._

នាយករដ្ឋមន្ត្រីជាប្រមុខរាជរដ្ឋាភិបាល មានភារៈទទួលខុសត្រូវរួមជាមួយសមាជិក ទាំងឡាយនៃរាជរដ្ឋាភិបាល ចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និង សកម្មភាពរបស់រាជរដ្ឋាភិបាល ។

មាត្រា ៩.-

នាយករដ្ឋមន្ត្រីដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែង បញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

មាត្រា ១០.-

នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំនិងជាអធិបតីអង្គប្រជុំ ។ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីសំរេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល ។

មាត្រា ១១.-

នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់កោះប្រជុំ និងធ្វើជាអធិបតីអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសំរេចកិច្ចការតាងនាមរាជរដ្ឋាភិបាលឡើយ ។

មាត្រា ១២.-

នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងការពារប្រទេស ។ នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិអោយសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាអ្នកចរចា និង ជាអ្នកចុះហត្ថលេខា ។

មាត្រា ១៣.-

នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសំរេច និងសារាចររបស់គណៈរដ្ឋមន្ត្រី។ លិខិតបទដ្ឋានទាំងនាំដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាលត្រូវតែបានចុះក្នុងរាជកិច្ច ។

មាត្រា ១៤.-

នាយករដ្ឋមន្ត្រីលើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាឱ្យកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ លើកសំណើស្តីពីសេចក្តីព្រាងច្បាប់និងសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច សមាជិករាជរដ្ឋាភិបាលជូនរដ្ឋសភាដើម្បីអនុម័ត ។

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយ ព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យនូវមន្ត្រី ជាន់ខ្ពស់ស៊ីវិលនិងយោធាដូចតទៅ ៖

- ទេសាភិបាលៈ ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង
- អធិការរាជរដ្ឋាភិបាល
- អភិបាលខេត្ត ក្រុង
- ឯកអគ្គរាជទូត
- ប្រៃសណីយ៍ទូរគមនាគមន៍និងពេញសមត្ថភាព
- នាយអគ្គសេនាធិការនិងនាយអគ្គសេនាធិការរង
- ឧត្តមសេនីយ៍ឡើងទៅ

មុខងារនិងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល និង យោធាមួយចំនួនផ្សេងទៀត និងត្រូវបាន តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យដែរ ស្របតាមការកំណត់ក្នុងលិខិតបទដ្ឋានដោយឡែកដែលបង្កើតដោយស្ថាប័ននោះ ។

មាត្រា ១៥._

នាយករដ្ឋមន្ត្រី តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា មន្ត្រីការទូត និងអភិបាលរង ខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ ដែលមិនមានចែងក្នុងមាត្រា ១៤ លើកលែងតែមន្ត្រីដែលមានចែងក្នុង មាត្រា ២៨ នៃច្បាប់នេះ ។

មាត្រា ១៦._

ក្នុងករណីពិសេស ឬ ប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់និងបន្ទាន់ រួចរាយការណ៍ទៅរដ្ឋសភាភ្លាម ។

មាត្រា ១៧._

នាយករដ្ឋមន្ត្រី ដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១៨._

ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រីទទួលភារងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។

ជំពូកទី ៣
សមត្ថកិច្ច សមាជិករាជរដ្ឋាភិបាល

មាត្រា ១៩._

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនាទុក្រមលើសមាជិកដទៃទៀត ។ ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។ កិច្ចការដែលទាក់ទងនិងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសំរេចឡើយ ។

មាត្រា ២០._

ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រី ដែលមិនដឹកនាំក្រសួងអាចទទួលភារកិច្ចតាមការកំណត់ របស់នាយករដ្ឋមន្ត្រី ។

មាត្រា ២១._

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំគ្រប់គ្រងក្រសួង ឬ រដ្ឋលេខាធិការដ្ឋានហៅថាប្រធានស្ថាប័ន ។

ប្រធានស្ថាប័នដឹកនាំការងារក្នុងស្ថាប័ន និងគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការដែលជាភ្នាក់ងាររដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋានដែលស្ថិតនៅក្រោមឱវាទ ។

មាត្រា ២២._

ប្រធានស្ថាប័ន មានភារកិច្ចដឹកនាំគ្រប់គ្រងស្ថាប័ននិងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់ ។

**មាត្រា ២៣.-**

ក្នុងករណីដែលក្រសួងត្រូវបានដឹកនាំ និង គ្រប់គ្រងដោយសហរដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងពីររូបមានសិទ្ធិអំណាចស្មើគ្នា ។ ក្នុងការដឹកនាំគ្រប់គ្រងក្រសួង ត្រូវឈរលើគោលការណ៍សហព័ទ្ធសំរេច ។

**មាត្រា ២៤.-**

ក្នុងករណីដែលក្រសួងត្រូវបានដឹកនាំនិងគ្រប់គ្រងដោយរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ រដ្ឋមន្ត្រីជាប្រធានស្ថាប័ន រដ្ឋលេខាធិការជាអនុប្រធានស្ថាប័ន ។ រដ្ឋលេខាធិការអនុវត្តតាមភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់ជូន ។ រាល់បញ្ហាធំៗ រដ្ឋមន្ត្រីត្រូវពិគ្រោះជាមួយរដ្ឋលេខាធិការមុននិងធ្វើសេចក្ដីសំរេចជាស្ថាពរ ។

**មាត្រា ២៥.-**

ក្រសួង ឬ រដ្ឋលេខាធិការដ្ឋានស្វយ័ត ដែលដឹកនាំដោយរដ្ឋលេខាធិការ រដ្ឋលេខាធិការជាប្រធានស្ថាប័ននោះ ។

**មាត្រា ២៦.-**

ក្នុងករណីដែលក្រសួងមានរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការជាប្រធានស្ថាប័ន អនុរដ្ឋលេខាធិការ ជួយកិច្ចការក្នុងក្រសួងតាមការប្រគល់ភារកិច្ចនៃប្រធានស្ថាប័ន ។

**មាត្រា ២៧.-**

អនុរដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័នចំណុះផ្ទាល់ទីស្ដីការគណៈរដ្ឋមន្ត្រី ដឹកនាំការងាររបស់ស្ថាប័ននោះ ក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ប៉ុន្តែនាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការណាម្នាក់ដឹកនាំគ្រប់គ្រងក៏បាន ។

**មាត្រា ២៨.-**

ប្រធានស្ថាប័នមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន វរសេនីយ៍ឯកនិងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ប្រធានស្ថាប័នមានសិទ្ធិតែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាននិងថ្នាក់ប្រហាក់ប្រហែល ។

មាត្រា ២៩.-

ប្រធានស្ថាប័នមានសិទ្ធិចេញប្រកាសនិងសារាចរ ។ សារាចរជាអត្ថបទសំរាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ ។ ប្រកាស ឬ សារាចររបស់ស្ថាប័ន មិនអាចចែងអំពីកិច្ចការអ្វីដែលមិនចូលក្នុងរង្វង់ក្របខ័ណ្ឌសមត្ថកិច្ចស្ថាប័នឡើយ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋាននានាដូចជាអនុក្រឹត្យ ឬសារាចររបស់រាជរដ្ឋាភិបាលដែរ ។

មាត្រា ៣០.-

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋានចាប់ពីថ្នាក់នាយកដ្ឋានឡើងត្រូវកំណត់ដោយអនុក្រឹត្យចាប់តាំងពីថ្នាក់នាយកដ្ឋានឡើង ។

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងនិង រដ្ឋលេខាធិការដ្ឋានចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាស ។

មាត្រា ៣១.-

រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អមដោយរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការព្រមទាំងមានអគ្គលេខាធិការរាជរដ្ឋាភិបាលផង គ្រប់គ្រង ចាត់ចែងការងារទីស្ដីការគណៈរដ្ឋមន្ត្រី សំរបសំរួលការងារប្រចាំថ្ងៃនៃគណៈរដ្ឋមន្ត្រី ក្រោមការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រី ។

តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការនឹងត្រូវបញ្ជាក់ដោយអនុក្រឹត្យស្ដីពីការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៣២.-

សមាជិកមួយៗ នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗ ខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្តនិងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដកនិងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលបានតាមបែបបទនិងនីតិវិធីជាធរមាន ។

## ជំពូកទី ៤

## ការបង្កើតក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

មាត្រា ៣៣.-

ការបង្កើតក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ត្រូវកំណត់ដោយច្បាប់ ។

## ជំពូកទី ៥
## អវសានបញ្ញត្តិ

**មាត្រា ៣៤.-**

ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ៩០ក្រ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩២ ព្រមទាំងលិខិតបទដ្ឋានអ្វីដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះជាស្ថាពរ ។

**មាត្រា ៣៥.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័ត
នៅភ្នំពេញ . ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤
ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១
ប្រធានរដ្ឋសភាស្តីទី

ឡូយ ស៊ីមឈាង